## ស្តង់ដារអប្បបរិមា (minimum standard)

វាសំដៅលើស្តង់ដារ ដែលរដ្ឋត្រូវប្រព្រឹត្តលើជនបរទេស ក្នុងប្រទេសរបស់ខ្លួនឲ្យបានសមស្រប ក្នុងកម្រិតអប្បបរិមាមួយ។ នេះជាស្តង់ដារអប្បបរិមាអន្តរជាតិ ហើយក្នុងករណី មិនបានគោរពតាមបានទេ រដ្ឋត្រូវប្រព្រឹត្តលើជនបរទេស ក្នុងកម្រិតអប្បបរមាជាតិ (national treatment standard)។

ក្នុងវិស័យយុត្តធម៌ គេយកការបដិសេធយុត្តិធម៌ (denial of justice) គឺជាម៉ែត្រវាស់វែង។ ប្រសិនបើមិនបានបំពេញទេ នោះវានឹងទំនងជាស្ថិតក្រោមកម្រិតស្តង់ដារអប្បបរិមា។ Denial of justice ក្នុងករណី មានការបង្អាក់មិនឲ្យជនបរទេសប្តឹងទៅតុលាការ (access to court) វិការៈធ្ងន់ធ្ងរក្នុងរដ្ឋបាល ឬដំណើរការផ្តល់ដំណោះស្រាយ សាលក្រមអយុត្តិធម៌ច្បាស់ក្រឡែត (manifestly unjust judgement) ឬ ការខកខានក្នុងការផ្តន្ទាទោស ជនដែលបង្ករបួសស្នាមដល់ជនបរទេស។

ពាក់ព័ន្ធនឹងទ្រព្យសម្បត្តិជនបរទេស ការដកហូត (expropriation) ត្រូវផ្តល់នូវសំណងដល់ពួកគេ ដោយពិចារណានូវបទប្បញ្ញត្តិច្បាប់ និងស្ថានភាពពាក់ព័ន្ធ។ ជាចុងក្រោយ ក្នុងវិស័យសិទ្ធិមនុស្ស ស្តង់ដារអប្បបរិមា តម្រូវឲ្យមានការប្រព្រឹត្តមិនរើសអើង (non-discrimination) (John P. Grant and J. Criag Barker, Encyclopedia Dictionary of International law, 3rd ed., 2009, pp. 303-304)។

**ខ្លឹមសារបន្ថែម៖** ក្នុងអត្ថន័យសិទ្ធិមនុស្ស ស្តង់ដារអប្បបរិមា ចែងនូវសិទ្ធិនិងកាតព្វកិច្ច។ វាជាស្តង់ដារកម្រិតទាប មួយដែលគេរំពឹងថា រដ្ឋទាំងអស់ ទោះបីប្រកាន់យករបបដឹកនាំបែបណា ប្រទេសតូច ឬធំ សុទ្ធតែអាចបំពេញតាមនូវស្តង់ដារនេះបាន។